# ប្រទេសកម្ពុជាស្ថិតក្រោមការពិនិត្យឡើងវិញនៃអនុសញ្ញា ស៊ី-ដ ៖ បញ្ជីបញ្ហា និងសំណួររបស់គណៈកម្មាធិការស៊ី-ដ

ចាប់ពីថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៩ដល់ ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៩ប្រទេសកម្ពុជាត្រូវបានពិនិត្យតាមដានដោយគណៈកម្មាធិការស៊ី-ដនៅក្នុងសម័យប្រជុំលើកទី៧៤របស់ខ្លួនទៅលើការអនុវត្តសិទ្ធិស្ត្រីដែលបានចែងនៅក្នុងអនុសញ្ញាស្តីពី ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (អនុសញ្ញា ស៊ី-ដ)។



នៅក្នុងការពិនិត្យនេះ ដោយផ្អែកទៅលើរបាយការណ៍របស់រាជរដ្ឋាភិបាលកម្ពុជា និងរបាយការណ៍ស្រមោលរបស់អង្គការសង្គមស៊ីវិល គណៈកម្មាធិការមានឱកាសក្នុងការសួរសំណួរបឋមទៅកាន់រាជរដ្ឋាភិបាលកម្ពុជា។ បញ្ជីបញ្ហា និងសំណួរនេះផ្តោតសំខាន់ទៅលើការព្រួយបារម្ភក្នុងការអនុវត្តអនុសញ្ញា ស៊ី-ដ របស់រដ្ឋាភិបាលកម្ពុជា។

## នេះជាបញ្ហាដែលគណៈកម្មាធិការអាចចោទសួរទៅកាន់ប្រទេសកម្ពុជានៅក្នុងកិច្ចប្រជុំពិនិត្យឡើងវិញ ៖

### ក្របខណ្ឌច្បាប់ និងគោលនយោបាយ

- វិធានការនានាត្រូវអនុវត្តដើម្បីធានាសិទ្ធិសេរីភាពក្នុងការជួបប្រជុំ សមាគម និងការបញ្ចេញមតិរបស់អ្នកការពារសិទ្ធិមនុស្សជាស្ត្រី ក៏ដូចជាសិទ្ធិឯកជនភាពរបស់ពួកគេផងដែរ។
- លទ្ធផលដែលសម្រេចបានតាមរយៈការអនុវត្តផែនការយុទ្ធសាស្ត្រថ្នាក់ជាតិសម្រាប់សមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រី បញ្ហាប្រឈមដែលបានជួបប្រទះ និងភាពខ្វះចន្លោះនានា។

### ជំនួយផ្នែកច្បាប់ និងការទទួលបានយុត្តិធម៌

វិធានការនានាក្នុងការបង្កើតគម្រោងជំនួយផ្នែកច្បាប់ឱ្យបានទូលំទូលាយដើម្បីធានាឱ្យស្ត្រីទទួលបានសេវាយុត្តិធម៌ប្រកបដោយប្រសិទ្ធភាពនៅតុលាការ ។

### ស្ត្រីក្នុងការឃុំខ្លួន

- វិធានការនានាដែលបានធ្វើឡើងក្នុងការធានាថាស្ត្រីដែលស្ថិតនៅក្នុងស្ថានភាពងាយរងគ្រោះនឹងមិនត្រូវបានឃុំឃាំងទាំងបំពាន ជាពិសេសស្ត្រីដែលប្រើប្រាស់គ្រឿងញៀន។
- វិធានការនានាដែលបានធ្វើឡើងដើម្បីអនុវត្តតាមច្បាប់ដែលមានស្រាប់ និងសេចក្តីណែនាំទៅលើជម្រើសផ្សេងៗដែលជំនួសឱ្យការឃុំខ្លួន។

### ផ្លាស់គំនិតរើសអើងទៅលើយេនឌ័រ

- ផលជះនៃវិធានការដែលធ្វើឡើងដើម្បីផ្លាស់ប្តូរផ្នត់គំនិតសង្គម និងវប្បធម៌ និងឥរិយាបថរបស់បុរស និងស្ត្រី ក៏ដូចជាការលុបបំបាត់បុរេវិនិច្ឆ័យ និងការប្រតិបត្តិតាមទំនៀមទម្លាប់ សុទ្ធតែផ្អែកទៅលើក្រមច្បាប់ស្រីដែលជាក្រមកំណត់ឥរិយាបថ និងតួនាទីរបស់ស្ត្រី និងបុរស។

### ការចូលរួម កិច្ចការសាធារណៈ និងនយោបាយ

- ព័ត៌មានស្តីពីផលប៉ះពាល់នៃវិធានការពាក់ព័ន្ធនឹងកំណើនសមាមាត្ររបស់តំណាងជាស្ត្រីក្នុងតួនាទីជាអ្នកសម្រេចចិត្ត។
- ថាតើរាជរដ្ឋាភិបាលកម្ពុជាបានពិនិត្យមើលលទ្ធភាពក្នុងការប្រើប្រាស់វិធានការពិសេសបណ្តោះអាសន្ន ដូចជាការកំណត់កូតាដើម្បីបង្កើនចំនួនស្ត្រីក្នុងកិច្ចការសាធារណៈ និងនយោបាយ ជាពិសេសនៅក្នុងតួនាទីជាអ្នកសម្រេចចិត្ត។

### ការអប់រំ

- ថាតើរាជរដ្ឋាភិបាលកម្ពុជាមានបំណងធ្វើឱ្យការអប់រំក្នុងកម្រិតបឋមសិក្សាជាកាតព្វកិច្ចចាំបាច់ដើម្បីធានាថា កុមារីមិនត្រូវបានបញ្ឈប់ពីសាលារៀនដើម្បី រកប្រាក់ចំណូលសម្រាប់គ្រួសារ ឬធ្វើកិច្ចការងារផ្ទះ ឬយ៉ាងណា។

### ការងារ

ចំពោះលក្ខខណ្ឌការងារ គណៈកម្មាធិការបានស្នើសុំក្នុងការផ្តល់ព័ត៌មានទៅលើ៖

- វិធានការនានាដែលត្រូវបានធ្វើឡើងក្នុងការធានាថានិយោជកនៃឧស្សាហកម្មដែលមានស្ត្រីជាច្រើនធ្វើការនឹងមិនត្រូវបានកេងចំណេញផលប្រយោជន៍ទៅលើពួកគេ ដោយការប្រើប្រាស់កិច្ចសន្យារយៈពេលខ្លីក្នុងរយៈពេលមួយវែង ឬដោយគ្មានការធានាអំពីសិទ្ធិការងាររបស់ពួកគេ ដូចជាការសម្រាកមាតុភាព និងការទទួលបានអត្ថប្រយោជន៍សង្គមជាដើម។
- វិធានការនានាត្រូវបានធ្វើឡើងដើម្បីធានាថា ស្ត្រីអាចចូលរួមប្រកបដោយប្រសិទ្ធភាពនៅក្នុងសហជីព រួមទាំងតួនាទីជាថ្នាក់ដឹកនាំផងដែរ។

### ស្ត្រីនៅជនបទ

- តើរាជរដ្ឋាភិបាលកម្ពុជានឹងធានាយ៉ាងដូចម្តេចដើម្បីឲ្យស្ត្រីនៅតាមជនបទមានឱកាសចូលរួមក្នុងការបង្កើតច្បាប់ និងគោលនយោបាយនៅក្នុងវិស័យដែលប៉ះពាល់ដល់សិទ្ធិរបស់ពួកគេ។

## ការឆ្លើយតបជាលាយលក្ខណ៍អក្សររបស់រដ្ឋភាគីទៅកាន់គណៈកម្មាធិការ ស៊ី-ដ

រាជរដ្ឋាភិបាលកម្ពុជាត្រូវបានស្នើឲ្យផ្តល់ការឆ្លើយតបក្នុងរយៈពេលពី ពីរ ទៅ បីខែ។ បញ្ជីបញ្ហា និងសំណួររួមជាមួយការឆ្លើយតបជាលាយលក្ខណ៍អក្សរពីរាជរដ្ឋាភិបាលកម្ពុជា ត្រូវមានភាពគ្រប់គ្រាន់សម្រាប់សមាជិកនៃគណៈកម្មាធិការមុនពេលកិច្ចប្រជុំ។ បញ្ជីបញ្ហា និងសំណួរអាចរកបាននៅតាមរយៈ ៖https://bit.ly/2K0yYFZ

ឧបត្ថម្ភដោយ

EUROPEAN UNION

DCA actalliance

ផលិតដោយ

VOICES for GENDER EQUALITY

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា Cambodian Center for Human Rights

@CCHRCambodia @CCHRCambodia @EU.Cambodia

BY NC SA

ខែមិថុនា ឆ្នាំ២០២០